# ពង្រីកការបើកបរចូលទៅកាន់ស្ពាន SPOKANE ST SWING BRIDGE ( ស្ពានទាប )

## ណួរដែលតែងសួរជាញឹកញាប់

### តើនាយកដ្ឋានដឹកជញ្ជូនក្រុងសៀអាថុល SDOT បង្កើតគោលការណ៍បើកបរចូលទៅស្ពានទាបថ្មីយ៉ាងដូចម្តេច ?

យើងដឹងហើយថាប្រជាជនដែលរស់នៅនិងធ្វើការនៅ តំបន់ភាគខាងលិចក្រុងសៀអាថុល West Seattle

ស្ថិតនៅក្នុងស្ថានភាពប្លែកនិងមិនធ្លាប់មានពីមុនមកទាក់ទងនឹងការបិទស្ពានខ្ពស់ក៏ដូចជាការតស៊ូជារៀងរាល់ថ្ងៃជាមួយនឹងការរីករាលដាលនៃជំងឺរាតត្បាតជាសកល។

យើងបានបន្តប្រមូលទិន្នន័យចរាចរណ៍អំពីចំនួនចរាចរណ៍លើស្ពានទាបចាប់តាំងពីយើងបានចាប់ផ្តើមអនុវត្តការផាកពិន័យដោយប្រើប្រព័ន្ធស្វ័យប្រវត្តិកម្មនៅខែមករាឆ្នាំ ២០២១។

កិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យទាំងនេះបានបង្ហាញថាគួរមានភាពរឹតបន្តឹងបន្ថែមនៅលើស្ពានទាប។

យើងបានទទួលមតិពីសមាជិកសហគមន៍ជាច្រើនតាមរយៈគំរោងអាស័យដ្ឋានអ៊ីម៉ែល និងការហៅចូលមកតាមទូរស័ព្ទ

ដែលបង្ហាញហេតុផលថាការបើកបរចូលទៅកាន់ស្ពានទាបអាចជួយបន្ធូរបញ្ហាបានច្រើន។ យើងក៏បានទាក់ទងទៅអាជីវកម្មនិងអង្គការនានាដែលស្ថិតនៅក្នុងតំបន់ខាងលិចក្រុងសៀអាថុល West Seattle ដោយផ្តោតលើសហគមន៍ដែលមានជនជាតិពណ៌សម្បុរចំរុះ ដើម្បីយល់កាន់តែច្បាស់ថែមទៀតពីបញ្ហាប្រឈមរបស់ពួកគេ។

ជាផ្នែកមួយនៃការធ្វើបច្ចុប្បន្នភាពគោលនយោបាយនេះ
យើងកំពុងពង្រីកអនុញ្ញាតការបើកបរចូលទៅកាន់ស្ពានទាបសម្រាប់ប្រជាជនដែលត្រូវការព្យាបាលពេទ្យសង្គ្រោះជីវិត, បុគ្គលិកពេទ្យដែលធ្វើការតាមការកោះហៅ, ភោជនីយដ្ឋាននិងអាជីវកម្មលក់របស់របរនៅតំបន់ខាងលិចក្រុងសៀអាថុល, និងអ្នកដទៃទៀតដែលប្រើប្រាស់ឡានវ៉ែន

ឡានធំដឹកអ្នកដំណើរឬឡានរដ្ឋការដែលជិះរួមគ្នាដែលមាន លេខផ្លាកឡានជិះរួមគ្នាដែលចេញដោយរដ្ឋ។.



យើងមិនអាចពង្រីកការបើកបរចូលនេះបានសំរាប់មនុស្សគ្រប់គ្នាបានទេ ដូច្នេះយើងត្រូវតែធ្វើការជ្រើសរើសគោលនយោបាយពិបាកៗមួយចំនួន។ យើងនឹងបន្តផ្សព្វផ្សាយដល់សហគមន៍នៅភាគខាងលិចក្រុងសៀអាថុល ហើយយើងនឹងបន្តតាមដាននិងវិភាគចំនួនចរាចរណ៍របស់យើងបន្តទៀត ដើម្បីយល់ពីរបៀបដែលការផ្លាស់ប្តូរគោលនយោបាយទាំងនេះជះឥទ្ធិពលយ៉ាងដូចម្តេចដល់ស្ថានភាពស្ពានទាប។

### តើខ្ញុំត្រូវដាក់ពាក្យសុំបើកបរចូលស្ពានទាបយ៉ាងដូចម្តេច ?

### តើខ្ញុំអាចទទួលបានជំនួយបំពេញពាក្យសុំនេះបានទេ ?

ដាក់ពាក្យតាមអ៊ីនធឺណិត៖: ពាក្យសុំក៏មាននៅគេហទំព័រ www.seattle.gov/transportation/lowbridge
ពាក្យសុំមានជាភាសាដូចខាងក្រោម៖
អង់គ្លេស, អេស្ប៉ាញ៉ុល, កូរ៉េ, សូម៉ាលី, ចិន(ប្រពៃណី). វៀតណាម, អូរ៉ូម៉ូ, និងខ្មែរ។
ដើម្បីស្នើសុំពាក្យសុំជាភាសាផ្សេងទៀតឬជាទម្រង់ក្រដាស សូមទាក់ទងមកយើងខ្ញុំ WestSeattleBridge@seattle.gov ឬ ២០៦-៤០០-៧៥១១ ។.



យើងរីករាយនឹងជួយអ្នកក្នុងការបំពេញសំណុំបែបបទស្នើសុំបើកបរចូល។ សូមផ្ញើសារអ៊ីម៉ែលមកយើងនៅ WestSeattleBridge@seattle.gov ឬទូរស័ព្ទមកយើងតាមរយៈលេខ (២០៦) ៤០០-៧៥១១ ហើយនឹងមានគេទាក់ទងមកអ្នកដើម្បីជួយអ្នក។.

ប្រសិនបើអ្នកឬនរណាម្នាក់ដែលអ្នកស្គាល់

មិនចេះនិយាយភាសាអង់គ្លេស ហើយត្រូវការជំនួយក្នុងការបំពេញបែបបទស្នើសុំឬមានសំនួរអ្វី សូមអ្នកទូរស័ព្ទមកលេខ (២០៦) ៤០០-៧៥១១ ហើយទុកដំណឹងនេះជាសំឡេង ឬផ្ញើសារអ៊ីមែលមក

WestSeattleBridge@seattle.gov. ។ សូមប្រាប់ឈ្មោះរបស់អ្នក ព័ត៌មានទំនាក់ទំនងនិងភាសាដែលត្រូវការ

យើងមានមនុស្សម្នាក់នឹងទូរស័ព្ទទៅអ្នកវិញ។

**Project Information and Contact**
Website: www.seattle.gov/transportation/lowbridge
Email: westseattlebridge@seattle.gov | Phone: (206) 400-7511

Seattle Department of Transportation

## ហេតុអ្វីបានជាត្រូវដាក់កម្រិតចរាចរណ៍នៅលើស្ពាន Spokane St Swing Bridge (ស្ពានទាប)?

នៅពេលដែលខ្ពស់ខាងលិចក្រុងសៀអាថុល West Seattle High-Rise Bridge (ស្ពានខ្ពស់) បានបិទនៅថ្ងៃទី ២៣ ខែមីនាឆ្នាំ ២០២០ ដោយសារបញ្ហាប្រេះស្ពាន យើងក៏បានចាប់ដាក់កម្រិតបណ្តឹងលើការបើកបរចូលទៅកាន់ស្ពាន Spokane St Swing Bridge (ស្ពានទាប)។

ស្ពានខ្ពស់អាចទ្រទ្រង់យានយន្តអោយធ្វើដំណើរបានច្រើន

ដោយហេតុថាវាមានលីងបើកបរដល់ទៅប្រាំពីរ បើប្រៀបធៀបទៅនឹងស្ពានទាបដែលមានលីងបើកបរតែពីរតែប៉ុណ្ណោះ។

ការប៉ុនប៉ងផ្លាស់ប្តូរចរាចរណ៍ទាំងស្រុងពីស្ពានខ្ពស់ទៅស្ពានទាបនឹងនាំឱ្យមានការកកស្ទះចរាចរណ៍និងយឺតយ៉ាវក្នុងការធ្វើដំណើរដោយប្រសិទ្ធិភាពដល់ឡានសង្គ្រោះបន្ទាន់ ឡានក្រុង និងឡានធំដឹកទំនិញ។



## តើការអនុវត្តច្បាប់ផាកពិន័យដោយរូបថតស្វ័យប្រវត្តិមានដំណើរការយ៉ាងដូចម្តេចនៅលើស្ពានទាប? តើខ្ញុំនឹងទទួលបានសំបុត្រផាកពិន័យ ៧៥ ដុល្លារ ដែរឬទេ?

ប្រសិនបើអ្នកមិនត្រូវបានអនុញ្ញាតឱ្យបើកបរលើស្ពានទាបទេ

អ្នកនឹងទទួលបានសំបុត្រផាកពិន័យ ៧៥

ដុល្លារៀងរាល់ពេលដែលអ្នកធ្វើដំណើរឆ្លងកាត់ស្ពានទាប។

ប្រព័ន្ធផាកពិន័យដោយថតរូបភាពស្វ័យប្រវត្តិ

នឹងថតរូបលេខផ្លាកឡានក្នុងកំឡុងពេលដែលស្ពានទាបត្រូវបានកម្រិត

នៅថ្ងៃធ្វើការចាប់ពីម៉ោង ៥ ព្រឹក ដល់ម៉ោង ៩ ល្ងាច និងនៅចុងសប្តាហ៍ ចាប់ពីម៉ោង ៨ ព្រឹក ដល់ ៩ យប់។

ប្រព័ន្ធផាកពិន័យដោយថតរូបភាពស្វ័យប្រវត្តិថតរូបយានយន្តដើម្បីថតទុកលេខផ្លាកឡាន ប៉ុន្តែមិនថតមនុស្សនៅខាងក្នុងរថយន្តនោះទេ។ រូបថតទាំងនេះត្រូវបានប្រើប្រាស់សម្រាប់អនុវត្តច្បាប់រឹតត្បិតលើស្ពានទាបហើយមិនមានបំណងសម្រាប់សកម្មភាពអនុវត្តច្បាប់ផ្សេងទៀតឡើយ។

ប្រព័ន្ធត្រួតពិនិត្យរូបថតស្វ័យប្រវត្តិនឹងបញ្ជូនលេខផ្លាកឡានទាំងអស់នោះទៅប្រៀបធៀបជាមួយនឹងទិន្នន័យលេខផ្លាកឡានរបស់អ្នកប្រើប្រាស់ដែលមានការអនុញ្ញាត ដើម្បីកំណត់ថាតើយានយន្តទាំងនោះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ស្ពានទាបនៅពេលនោះដែរឬទេ។

មន្ត្រីនគរបាលនៃក្រុងសៀអាថុលនឹងពិនិត្យមើលរូបភាពនៃរាល់ការរំលោភដែលអាចកើតមាន មុនពេលផ្ញើសំបុត្រផាកពិន័យ ៧៥ ដុល្លារ ចេញទៅ។

រថយន្តសង្គ្រោះបន្ទាន់ រថយន្តក្រុងនិងរថយន្តដឹកទំនិញមិនចាំបាច់ផ្តល់លេខស្លាកឡានរបស់ខ្លួនដល់នាយកដ្ឋានដឹកជញ្ជូនក្រុងសៀអាថុល SDOT ឡើយ។

## ប្រសិនបើខ្ញុំមិនអាចបើកបរលើស្ពានទាបបាន តើខ្ញុំត្រូវធ្វើយ៉ាងម៉េចដើម្បីធ្វើដំណើរទៅមកពីតំបន់ខាងលិចក្រុងសៀអាថុល West Seattle?

ផ្លូវជំនួសសម្រាប់អ្នកដែលធ្វើដំណើរទៅនិងមកពីខាងលិចទីក្រុងសៀអាថុលដោយរថយន្ត គឺអាចបើកតាមផ្លូវស្ពាន 1ST Ave S Bridge ឬស្ពាន South Park Bridge បាន។

ស្ពានទាបក៏បើកសម្រាប់អ្នកផងដែរប្រសិនបើអ្នកជិះឆ្លងកាត់តាមឡានក្រុង ឡានវ៉េនជិះជាក្រុម ឆ្លងកាត់ដោយថ្មើរជើង រំកិល ឬដោយជិះរទេះម៉ូតូអគ្គិសនីឬជិះកង់។ អ្នកបើករថយន្តសង្គ្រោះបន្ទាន់ ឡានក្រុងសាធារណៈ និងរថយន្តដឹកទំនិញ អាចប្រើស្ពានបានគ្រប់វេលា។



យើងកំពុងធ្វើការដើម្បីជួយធ្វើឱ្យផ្លូវវាងកាន់តែងាយស្រួល ដោយការធ្វើស្លាកសញ្ញាជាថ្មីនៅលើផ្លូវកែសម្រួលពេលវេលាភ្លើងសញ្ញា និងកែលម្អសញ្ញាផ្លូវផងដែរ។ យើងក៏កំពុងធ្វើការជាមួយសហគមន៍ដែលនៅក្បែរៗនោះដើម្បីផ្តល់អាទិភាពដល់គម្រោងនានាដែលនឹងកាត់បន្ថយភាពប៉ះពាល់នៃការកើនឡើងចរាចរណ៍លើផ្លូវបើកវាងទាំងអស់នេះ ហើយផ្តល់អាទិភាពដល់ការតភ្ជាប់ផ្លូវឆ្លងកាត់ទៅនិងមកពីខាងលិចក្រុងសៀអាថុល។ កសាងគំរោងថ្មីនិងបង្កើតនិងកែលំអផ្លូវវាងទាំងអស់នេះ។

ដើម្បីទទួលបានជំនួយការធ្វើដំណើររបស់អ្នក សូមចូលមើលគេហទំព័រថ្មី ការជ្រើសរើសធ្វើដំណើរ West Seattle និង Duwamish Valley តាមគេហទំព័រ៖ https://www.seattle.gov/transportation/west-seattle-travel-options/



## តើមានអ្វីកើតឡើងប្រសិនបើមានអាសន្នហើយខ្ញុំត្រូវការបើកឆ្លងកាត់ស្ពានទាប?

យើងដឹងថាភាពអាសន្នអាចកើតឡើង ហើយអ្នកប្រហែលជាត្រូវបើកឡានទៅមន្ទីរពេទ្យដោយខ្លួនឯង ជំនួសការហៅរថយន្តសង្គ្រោះបន្ទាន់។

ឥឡូវនេះការអនុវត្តន៍ផាកពិន័យ

ដោយស្វ័យប្រវត្តិបានចាប់ផ្តើម ហើយ សំបុត្រផាកពិន័យ ៧៥ ដុល្លារ

នឹងត្រូវផ្ញើទៅមនុស្សទាំងអស់ដែលបានបើកបរយានយន្តដែលគ្មានការអនុញ្ញាតឆ្លងកាត់ស្ពានទាប នៅថ្ងៃធ្វើការចាប់ពីម៉ោង ៥ ព្រឹក ដល់ម៉ោង ៩ យប់ និងនៅចុងសប្តាហ៍ ចាប់ពីម៉ោង ៨ ព្រឹក ដល់ម៉ោង ៩ យប់។

សំបុត្រផាកពិន័យ ៧៥ ដុល្លារ នេះនឹងមានការណែនាំអំពីវិធីតវ៉ា។

យើងមិនអាចធានាថាអ្នកនឹងរួចពីការបង់ប្រាក់ផាកពិន័យនេះទេ

ព្រោះការផាកពិន័យនេះនឹងត្រូវសំរេចដោយតុលាការក្រុងសៀអាថុល។